ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ០៦៤/១៤ សាណ-១៤ អអក

ភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៤

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការបញ្ចុះអត្រាថ្លៃផ្គត់ផ្គង់អគ្គិសនីនៅនៅឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ របស់សេវាករ ញាណ វឌ្ឍនា

អាជ្ញាធរអគ្គិសនីកម្ពុជា សូមប្រកាសជូនសាធារណជនដែលជាអ្នកប្រើប្រាស់អគ្គិសនី និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់សេវាករ ញាណ វឌ្ឍនា នៅឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ មេត្តាជ្រាបថា លើមូលដ្ឋាននៃយុទ្ធសាស្ត្រពង្រីកប្រភពអគ្គិសនីចេញពីអនុស្ថានីយ ដែលមានថ្លៃសមរម្យទៅជំនួសប្រភពអគ្គិសនីបានពីការផលិតអគ្គិសនីដោយប្រើប្រេងម៉ាស៊ូតដែលមានថ្លៃខ្ពស់ អាជ្ញាធរអគ្គិសនីកម្ពុជា បានសម្រេចអនុញ្ញាតឲ្យ**អគ្គិសនីកម្ពុជា** ធ្វើការវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនវងអគ្គិសនី ដែលមានប្រភពមកពីអនុស្ថានីយ៍ខេត្តបាត់ដំបង របស់អគ្គិសនីកម្ពុជា មកផ្គត់ផ្គង់លក់ដុំឲ្យសេវាករ ញាណ វឌ្ឍនា ធ្វើសេវាកម្មចែកចាយអគ្គិសនីនៅឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលបានដាក់ឲ្យប្រើប្រាស់កន្លងមក រហូតបច្ចុប្បន្ន ហើយទទួលបាននូវការផ្គត់ផ្គង់អគ្គិសនីមួយមានស្ថេរភាព គុណភាព និងមានការបញ្ចុះថ្លៃជាបន្តបន្ទាប់ដែរ។ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចបញ្ចុះថ្លៃលក់អគ្គិសនី នៅតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ញាណ វឌ្ឍនា ពីអត្រាថ្លៃលក់ ៣,១០០ រៀល/គីឡូវ៉ាត់ម៉ោង មកអត្រាថ្លៃលក់ ១,១០០ រៀល/គីឡូវ៉ាត់ម៉ោង លើថាមពលប្រើប្រាស់ចាប់ពីខែធ្នូ ឆ្នាំ២០១៤ នេះតទៅ ដូចតំបន់ដទៃទៀតនៅក្នុងខេត្តពោធិ៍សាត់។

អាស្រ័យហេតុនេះ សូមអ្នកប្រើប្រាស់អគ្គិសនី អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ ញាណ វឌ្ឍនា នៅឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ មេត្តាជ្រាបជាពត៌មាន ដោយអនុគ្រោះ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**

ចម្លងជូន

- សាលាខេត្តពោធិ៍សាត់
- មន្ទីររ៉ែ និងថាមពល ខេត្តពោធិ៍សាត់
- សាលាស្រុកបាកាន
- សាលាឃុំតាលោ
  "ដើម្បីជូនជ្រាប"
- សេវាករ ញាណ វឌ្ឍនា
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងកើតវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ